# Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយបន្ទាន់

# ប្រទេសជប៉ុនផ្ដល់ថវិកា ៣,៩ លានដុល្លារ ដើម្បីដោះស្រាយ បញ្ហាទឹកជំនន់និង គ្រោះរាំងស្ងួតរបស់មេគង្គ

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០២០** – រដ្ឋាភិបាលជប៉ុន ថ្ងៃនេះ បានផ្ដល់ថវិកាចំនួន ៤១២ លានយ៉េន ឬ ប្រមាណ ៣,៩ លានដុល្លារអាមេរិក ដល់គណៈកម្មការទន្លេមេគង្គ (MRC) ដើម្បីធ្វើឱ្យមុខងារត្រួតពិនិត្យ និងព្យាករណ៍ទឹកជំនន់ និងគ្រោះរាំងស្ងួត មានភាពប្រសើរឡើង។

ជំនួយនេះ ធ្វើឡើងក្នុងរយៈពេលបួនឆ្នាំ គិតចាប់ពីឆ្នាំ ២០២០ ដល់ឆ្នាំ ២០២៣។ ថវិកាទាំងនេះគឺសំដៅប្រែក្លាយ មជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់និងរាំងស្ងួតប្រចាំតំបន់ (RFDMC) ដែលមានទីតាំងនៅក្រុងភ្នំពេញ ឱ្យទៅជាមជ្ឈមណ្ឌលឈានមុខគេ ក្នុងការផ្ដល់ការព្យាករណ៍អំពីទឹកជំនន់និងគ្រោះរាំងស្ងួតឱ្យកាន់តែលឿន និងសុក្រិតជាងមុន ទៅដល់បណ្ដាប្រទេសតាមដងទន្លេមេគង្គក្រោម រួមមាន កម្ពុជា ឡាវ ថៃ និងវៀតណាម។

សកម្មភាពសំខាន់ៗមួយចំនួន ដែលមូលនិធិនេះនឹងគាំទ្រ គឺការធ្វើឱ្យប្រសើរឡើងនូវព័ត៌មានសាធារណៈ ស្ដីពីទឹកជំនន់ និងគ្រោះរាំងស្ងួត តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងដឿនលឿនជាងមុន។ ព័ត៌ទាំងនេះ នឹងធ្វើឱ្យសហគមន៍មូលដ្ឋាន និងរដ្ឋាភិបាលរបស់ប្រទេសតាមដងទន្លេមេគង្គទទួលបានការជូនដំណឹងទាន់ពេលវេលា ហើយអាចកាត់បន្ថយការខូចខាតនានា នៅពេលមានគ្រោះមហន្តរាយ។ វាក៏នឹងជួយសម្រួលដល់ការធ្វើសមាហរណកម្មមុខងារគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ដើម្បីផ្ដល់ការព្យាករណ៍មួយ ដែលមានរយៈពេលវែងជាងមុន និងសុក្រិតជាងមុន។

បណ្ឌិត អាន ពេជ្រហត្ថដា នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC បាននិយាយថា "ជំនួយនេះនឹងធ្វើឱ្យគណៈកម្មការទន្លេមេគង្គ អាចបង្កើននូវសមត្ថភាពរបស់ខ្លួន ក្នុងការព្យាករណ៍ទឹកជំនន់ និងភាពរាំងស្ងួត ឱ្យបានប្រសើរជាងមុន ក្នុងគោលបំណងបន្តជួយដល់ប្រទេសជាសមាជិក និងសហគមន៍ងាយរងគ្រោះ ពីបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួត ប្រកបដោយប្រសិទ្ធភាព" ។ លោកបានលើក ឡើងដូច្នេះ នៅក្នុងពិធីចុះហត្ថលេខា ដែលបានធ្វើឡើងនៅទីស្នាក់ការកណ្ដាលនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គក្នុងទីក្រុងវៀងចន្ទ។

រដ្ឋាភិបាលជប៉ុន គឺជាដៃគូអភិវឌ្ឍន៍មួយ ក្នុងចំណោមដៃគូអភិវឌ្ឍន៍ជាយូរមកហើយរបស់ MRC។ ចាប់តាំងពីឆ្នាំ ២០០១ មក រដ្ឋាភិបាលជប៉ុនបានផ្ដល់ថវិកាជាង ១៨ លានដុល្លារ ដើម្បីគាំទ្រគម្រោងជាច្រើន ដូចជា គម្រោងគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ធារាសាស្ត្រ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងបរិស្ថានជាដើម។

ក្នុងឆ្នាំ ២០០៤ មូលនិធិជប៉ុន បានជួយដល់គណៈកម្មការទន្លេមេគង្គ សាងសង់មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់ (RFMMC) ដែលពេលនេះត្រូវបានប្តូរឈ្មោះថា មជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់និងរាំងស្ងួតប្រចាំតំបន់ (RFDMC)។ មជ្ឈមណ្ឌល RFMMC បានបំពាក់ឧបករណ៍ និងបច្ចេកវិទ្យាចាំបាច់នានា សម្រាប់ផ្តល់ព័ត៌មានព្យាករណ៍កម្ពស់ទឹកជំនន់ និងត្រួតពិនិត្យកម្ពស់ទឹកទន្លេប្រចាំថ្ងៃដល់តំបន់មេគង្គក្រោម។

ជាមួយនឹងការគាំទ្រហិរញ្ញវត្ថុនាពេលបច្ចុប្បន្ននេះ ជប៉ុនជឿថា វានឹងជួយពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មការទន្លេមេគង្គ ក្នុងការដោះស្រាយបញ្ហាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអាងទន្លេមេគង្គក្រោម ដែលជានិច្ចជាកាល ប្រឈមនឹងគ្រោះមហន្តរាយអស់ទាំងនេះ។

ថ្លែងក្នុងពិធីចុះហត្ថលេខា នាថ្ងៃសុក្រទី ១៣ ខែមីនានេះ លោក Keizo Takewaka ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំប្រទេសឡាវ បាននិយាយថា “ការគាំទ្រហិរញ្ញវត្ថុនេះ តំណាងឱ្យការជឿទុកចិត្ត និងភាពជឿជាក់របស់ជប៉ុនលើគណៈកម្មការទន្លេមេគង្គ ក្នុងការងាររបស់គណៈកម្មការនេះ ដើម្បីកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ និងលើកកម្ពស់ការគ្រប់គ្រងធនធានទឹកក្នុងអាងទន្លេមេគង្គ” ។

## កំណត់សម្គាល់សម្រាប់និពន្ធនាយក៖

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

**-ចប់-**

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក មាស សុភក្រ្គ
មន្រ្តីទំនាក់ទំនងស្តីទីជាមួយអ្នកសារព័ត៌មាន
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទ៖ +856-21-263263, ភ្ជាប់បន្ត 4012
ទូរសព្ទដៃ៖ +856-20-77779168

###